care

Australian Aid

ACCESS
Sustainable quality services for all

# អត្ថបទរំលេចអំពីការផ្លាស់ប្តូរវិជ្ជមានសំខាន់ៗ៖

# ការធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាសុខភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រក្នុងខេត្តរតនគិរី

## សេវាសុខភាពក្នុងខេត្តរតនគិរីនៅមានកម្រិត

សេវាសុខភាពជាផ្នែកមួយដ៏សំខាន់នៃកញ្ចប់សេវាសំខាន់ៗដើម្បីឆ្លើយតបនឹងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ(GBV)។GBV មិនត្រឹមតែប៉ះពាល់សុខភាពរាងកាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងស្មារតីផងដែរ។ អ្នកផ្តល់សេវាសុខភាព គឺស្ថិតក្នុងចំណោមអ្នកដំបូងគេដែលជួបជនរងគ្រោះដោយ GBV ដោយសារគេនៅក្បែរសហគមន៍។ ប៉ុន្តែដោយសារតែកង្វះនៃការគាំទ្រនិងឱកាសទទួលបានការបណ្តុះ បណ្តាលអំពីការឆ្លើយតបនឹងGBVនៅមានកម្រិតអ្នកផ្តល់សេវាសុខភាពភាគច្រើនមានចំណេះដឹងមិនគ្រប់គ្រាន់អំពី GBV និងផលប៉ះពាល់របស់វាទៅលើសុខភាពផ្លូវកាយ និងផ្លូវចិត្ត។កង្វះចំណេះដឹងទាក់ទងនឹងGBVក៏សបញ្ជាក់ឱ្យឃើញពីការរៀបចំមូលដ្ឋានសុខាភិបាលនិងការផ្តល់សេវាពោលគឺកង្វះទីកន្លែងសេវាមានភាពឯកជនសមស្រប ហើយអ្នកផ្តល់សេវាសុខភាពមិនអាចផ្តល់ប្រឹក្សាយោបល់និងគ្រប់គ្រងភាពតានតឹងផ្លូវចិត្តរបស់ជនរងគ្រោះពី GBV បានជាដើម។ អត្ថបទនេះមានគោលបំណងបង្ហាញពីការផ្លាស់ប្តូរសំខាន់ៗនៅក្នុងការឆ្លើយតបនឹង GBV ក្នុងវិស័យសុខាភិបាលបន្ទាប់ពីអង្គការឃែរកម្ពុជា (CARE)បានអនុវត្តគម្រោងនៅក្រុងបានលុង ស្រុកអូរយ៉ាដាវ និងស្រុកអណ្តូងមាស ខេត្តរតនគិរីដោយទទួលបានហិរញ្ញប្បទានពី ACCESS ។

រតនគិរីជាខេត្តស្ថិតនៅភូមិភាគឦសាននៃប្រទេសកម្ពុជាដោយមានប្រជាជនភាពច្រើនលើសលុបជាជនជាតិដើមភាគតិច។ នៅក្នុងតំបន់នេះ បើតាមបុគ្គលិកអង្គការឃែរបញ្ជាក់ថាករណី GBV កើតមានច្រើនហើយគេ មិនរាយការណ៍ទៅអជ្ញាធរទេ។ ការដោះស្រាយករណីGBVធ្វើជាលក្ខណៈប្រពៃណីហើយជារឿយៗមានការលើកលែងទោសដល់ជនល្មើសដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិនិងយុត្តិធម៌សម្រាប់ស្ត្រីនិងកុមារី។ ជាឧទាហរណ៍ ក្នុងករណីការរំលោភបំពានផ្លូវភេទជាច្រើន ក្រុមគ្រួសារធ្វើតាមពាក្យរបស់គ្រូបុរាណ (Sharma[1] ) ហើយ ប្រើមធ្យោបាយដោះស្រាយជម្លោះ ដោយផ្តល់សំណងដល់គ្រួសាររបស់ស្ត្រី ឬក្មេងស្រីរងគ្រោះនូវគោក្របី និង/ឬប្រាក់កាស។ ក្នុងករណីខ្លះដើម្បីដោះស្រាយករណីរំលោភ ក្មេងស្រីបានរៀបការជាមួយបុរស ដោយមានការព្រមព្រៀងគ្នារវាងគ្រួសារខាងប្រុស និងខាងស្រី។

មុនពេលការងាររបស់អង្គការឃែរ ចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ២០១៩ ករណី GBV ចំនួនតិចតួច ត្រូវបានរាយការណ៍ទៅអាជ្ញាធរ ហើយជនរងគ្រោះពី GBV ទៅរកសេវានៅមណ្ឌលសុខភាព ដើម្បី ព្យាបាលរបួសរាងកាយទូទៅ។ បុគ្គលិកម្នាក់នៅមណ្ឌលសុខភាពអូរយ៉ាដាវ បានអះអាងថា *“កាលពីមុន យើងកម្រឃើញករណី GBV មករកយើង ដើម្បីទទួលសេវា GBV ណាស់។ បើពួកគេមក យើងក៏មិនដឹងថាត្រូវផ្តល់សេវាអ្វីដែរ»*។

1 មនុស្សចាស់ជរាប្រចាំភូមិ ដែលមានប្រជាជនសហគមន៍គោរព និងជឿថាមានប្រាជ្ញា និងទស្សន៍ទាយអនាគត

## សារៈសំខាន់នៃការផ្លាស់ប្តូរ

ការផ្លាស់ប្តូរដែលបានរាយការណ៍នេះចាត់ទុកថាសំខាន់ដោយឆ្លុះបញ្ចាំងពីភស្តុតាងបង្ហាញថាការផ្លាស់ប្តូរដែលបានរាយការណ៍អាចមានលើសពីកម្មវិធី ។

ភស្តុតាងបង្ហាញថា ការផ្លាស់ប្តូរត្រូវបានកើតឡើងជាប្រព័ន្ធនៅក្នុងមូលដ្ឋានថែទាំសុខភាដោយមានការយោគយល់គ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការជាមួយមន្ទីរសុខាភិបាល ក្នុងការផ្តល់សេវា GBV ដល់ជនរងគ្រោះនៅក្នុងសហគមន៍។

## កម្រិតនៃការចូលរួមចំណែករបស់កម្មវិធី

កម្រិតនៃវិភាគទាន ក្នុងការផ្លាស់ប្តូរត្រូវបានវាយតម្លៃថាមានសំខាន់សម្រាប់ទាំងចំណេះដឹងនិងជំនាញរបស់បុគ្គលិកសុខាភិបាលនិងការរៀបចំមូលដ្ឋានសុខាភិបាលដើម្បីសម្របសម្រួលករណី។

អ្នកផ្តល់បទសម្ភាសនជឿជាក់ថាបើគ្មានការងារអភិវឌ្ឍន៍សមត្ថភាពរបស់អង្គការក្រោមជំនួយហិរញ្ញវត្ថុរបស់ទេ កាផ្លាស់ប្តូរដែលបានរៀបរាប់ក្នុងអត្ថបទនេះ ប្រហែលជាមិនអាចកើតឡើងទេ។

**អាសយដ្ឋាន:** អគារលេខ ២៤០ ជាន់ទី៣ អគារ អានីណា ផ្លូវ ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ទូរស័ព្ទ:** (៨៥៥) ១២ ៨៧៦ ៥៤៩

**អ៊ីម៉ែល:** info@accesscambodia.org

**វេបសាយ:** www.accesscambodia.org

ខណៈមណ្ឌលសុខភាពផ្តល់ការព្យាបាលរបួសរាងកាយ សេវាសុខាភិបាលមិនដឹងថាជួយជនរងគ្រោះបញ្ចកង្វល់ផ្លូវចិត្តនិងសុវត្ថិភាពរបស់គេរបៀបណាទេ។ការព្យាបាលកើតឡើងជាមួយគ្នាក្នុងកន្លែងរួមគ្នាជាមួយអ្នកជំងឺទូទៅដោយមិនគោរពតាមស្តង់ដារឯកជនភាពដែលមាន ក្នុងគោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនៅក្នុងប្រព័ន្ធសុខាភិបាលទេ។ ម៉្យាងវិញទៀត អ្នកផ្តល់សេវាសុខភាពមានចំណេះដឹងមិនគ្រប់គ្រាន់អំពីការផ្តល់ការប្រឹក្សាយោបល់ដល់ជនរងគ្រោះពី GBV មិនអាចផ្តល់ដំបូន្មានដល់អតិថិជនអំពីដំណោះស្រាយនានា ការវាយតម្លៃសុវត្ថិភាពអតិថិជន ការរក្សាកំណត់ត្រាសុវត្ថិភាពការរាយការណ៍និងការបញ្ជូនបន្តទៅរកសេវាចាំបាច់ផ្សេងទៀត។តាមសម្តីរបស់បុគ្គលិកមណ្ឌលសុខភាពអូរយ៉ាដាវបាននិយាយថា *“ពីមុនយើងអាចផ្តល់ការព្យាបាលរបួសរាងកាយដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារប៉ុណ្ណោះ។ ក្រោយពីព្យាបាលរួចយើងគ្រាន់តែឲ្យជនរងគ្រោះត្រឡប់ទៅផ្ទះវិញហើយដោះស្រាយបញ្ហាវិវាទរបស់ពួកគេដោយខ្លួនឯង ព្រោះយើងមិនដឹងត្រូវធ្វើយ៉ាងណានោះទេ”។*

## ការពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាល និងការរៀបចំមូលដ្ឋានសុខាភិបាល

ដោយមានជំនួយផ្នែកហិរញ្ញវត្ថុពីកម្មវិធី ACCESS ទើបជួយធ្វើឱ្យអង្គការ CARE អនុវត្តការងាររបស់ពួកខ្លួន ដែលមានការផ្លាស់ប្តូរជាវិជ្ជមានជាច្រើននៅក្នុងសេវាសុខភាពរបស់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក នៅក្នុងតំបន់គោលដៅ។



សកម្មភាពបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលនៅមណ្ឌលសុខភាពតាឡាវGBV

ការគាំទ្រនេះបានជួយធ្វើឱ្យអង្គការធ្វើការសហការជាមួយមន្ទីរសុខាភិបាលខេត្តដើម្បីពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាលនៅក្នុងតំបន់គោលដៅ។ រវាងខែតុលា ឆ្នាំ ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២០ បុគ្គលិកសុខាភិបាលសរុបចំនួន ៤៩នាក់មកពីមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកគោលដៅ ទទួលបានវគ្គបណ្តុះ បណ្តាល ស្តីពី "គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនៅក្នុងប្រព័ន្ធសុខាភិបាល" ការបណ្តុះបណ្តាលអាកប្បកិរិយា ការបៀតបៀនផ្លូវភេទ និងការវិភាគសង្គម និងសកម្មភាពស្តង់ដារអប្បបរមា នៃការប្រឹក្សាយោបល់ជាមូលដ្ឋាន និងការបញ្ជូនបន្ត។ គ្រូបង្គោលមន្ទីរសុខាភិបាល បន្តហ្វឹកហ្វឺន និងគាំទ្រផ្នែកត្រួតពិនិត្យសម្រាប់បុគ្គលិកសុខាភិបាលដែលបានទទួលការបណ្តុះបណ្តាលផងដែរ។

បទអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពទាំងនេះ បានជួយពង្រឹងចំណេះដឹង និងសមត្ថភាពរបស់បុគ្គលិកសុខាភិបាលក្នុងការឆ្លើយតបទៅនឹងករណី។ នេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈ ការកើនឡើងជាមធ្យមនៃលទ្ធផលមុន និងក្រោយការធ្វើតេស្តសាកល្បងលើប្រធានបទបណ្តុះបណ្តាលទាំងប្រាំ។ ភាគរយនៃបុគ្គលិកសុខាភិបាលដែលឆ្លើយសំណួរសាកល្បងត្រឹមត្រូវបានកើនឡើងជាមធ្យមចំនួន ៣០% បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល (ពី ៥០% ទៅ ៨០%)។ ម៉្យាងវិញទៀត



របាយការណ៍ហ្វឹកហ្វឺនពីមន្ទីរសុខាភិបាលក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០២០បានបង្ហាញពីលទ្ធផលការងារល្អក្នុងការផ្តល់សេវារបស់បុគ្គលិកសុខាភិបាលដែលបានទទួលកាបណ្តុះបណ្តាល។ របាយការណ៍នេះបានលើកឡើងថា "រហូតមកដល់ពេលនេះអ្នកផ្តល់សេវាដែលទទួលការបណ្តុះបណ្តាលប្រមាណ ៧៣% អាចផ្តល់សេវាបានដោយអនុលោមតាមស្តង់ដារសេវាសុខភាព" ។ បុគ្គលិកសុខាភិបាលមកពីមណ្ឌលសុខភាព អូរយ៉ាដាវ បានយល់ស្របនឹងការផ្លាស់ប្តូរនេះហើយបានបន្ថែមថា *"បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលឥឡូវនេះខ្ញុំអាចផ្តល់ការគាំទ្រផ្សេងៗដល់អតិថិជនរួមទាំងជំនួយសុខភាពផ្លូវចិត្តការបញ្ជូនបន្តទៅកាន់ទីជម្រកសុវត្ថិភាពការសម្របសម្រួលជាមួយឃុំនិងមន្ត្រីនគរបាលដើម្បីទទួលបានការគាំទ្របន្ថែមសម្រាប់ជនរងគ្រោះ និងការបញ្ជូនជនរងគ្រោះមកធ្វើកោសល្យវិច្ច័យនៅមន្ទីរពេទ្យបង្អែក ។ល។”*

កិច្ចសហការដ៏ល្អរវាងអង្គការ CARE និងមន្ទីរសុខាភិ បាលខេត្ត ក្នុងការកសាងសមត្ថភាពបុគ្គលិកសុខាភិបាលតាមរយៈការបណ្តុះបណ្តាលជាបន្តបន្ទាប់ ក៏បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការយល់ដឹងពីGBV និងបរិយាបន្ននៅក្នុងការប្រកបការងារនៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក គោលដៅទាំងនោះ។ មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកនីមួយៗបានចាត់តាំងយ៉ាងហោចណាស់បុគ្គលិកសុខាភិបាលម្នាក់ដែលទទួលខុសត្រូវចំពោះអតិថិជន GBV។ ពួកគេក៏បានចាត់តាំងបុគ្គលិកសុខាភិបាលជនជាតិដើមភាគតិចធ្វើជាអ្នកបកប្រែដើម្បីជួយដល់អតិថិជនGBVជាជនជាតិដើមភាគតិចផងដែរ។លើសពីនេះ មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ទាំងនេះក៏បានរៀបចំបន្ទប់ឯកជនមួយសម្រាប់ផ្តល់សេវា GBV តែម៉្យាងនិងបង្កើតទម្រង់ ដើម្បីកត់ត្រាករណី GBV។ ការរៀបចំដែលបានផ្លាស់ប្តូរនេះ ធ្វើឡើងដើម្បីធានាឱ្យមានឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់អតិថិជន ខណៈទទួលបានសេវាដោយអនុលោមតាមគោលការណ៍ណែនាំជាតិ។ សមាជិកបុគ្គលិកសុខាភិបាលម្នាក់បាននិយាយថា *“បន្ទប់ឯកជននេះមានប្រយោជន៍ណាស់ព្រោះពេលខ្លះជនរងគ្រោះពី GBV មិនមានចេតនាចង់ប្រាប់បញ្ហារបស់ពួកគេមកពួកយើងនៅក្នុងបន្ទប់រួមនោះទេប៉ុន្តែនៅពេលយើងនាំពួកគេទៅក្នុងបន្ទប់ឯកជនដែលមានតែពួកយើងពីរនាក់ពួកគេចាប់ផ្តើមនិយាយពីបញ្ហារបស់ពួកគេបណ្តើរៗ។ ហើយដោយសារតែសមត្ថភាពនិងជំនាញក្នុងការប្រឹក្សាយោបល់របស់យើងទើបយើងអាចបញ្ចុះបញ្ចូលជនរងគ្រោះឱ្យមានអារម្មណ៍ស្រួលក្នុងការពិភាក្សាអំពីបញ្ហារបស់ពួកគេជាមួយយើងព្រមទាំងមានទំនុកចិត្តលើសមត្ថភាពរបស់យើងក្នុងការគាំទ្រពួកគេ ដោះស្រាយបញ្ហារបស់ពួកគេផ្ទាល់ ”*។ បន្ថែមលើការផ្លាស់ប្តូរជាវិជ្ជមាននេះ របាយការណ៍វាយតម្លៃគម្រោង CARE ក៏បានលើកឡើងពីការពេញចិត្តរបស់អតិថិជន GBV នូវសេវាសុខភាពដោយលើកឡើងថា"អ្នកផ្តល់សេវាសុខភាពគួរឱ្យគោរព និងរួសរាយរាក់ទាក់ចំពោះពួកគេ"។



បុគ្គលិកមណ្ឌលសុខភាពកញ្ចាញ ផ្តល់សេវាប្រឹក្សាយោបល់ដល់ជនរងគ្រោះពី GBV នៅក្នុងបន្ទប់ឯកជនមួយដែលរៀបចំឡើងសម្រាប់សម្របសម្រួលករណី GBV